# ឋ

**ឋ** ព្យញ្ជនៈ ទី ១២ ក្នុងវគ្គទី ៣ ជាមុទ្ធជៈ មានសំឡេងកើតក្នុងក្បាល គឺមានសំឡេងលាន់ឮទៅខាងក្បាល ផ្សេងពីសំឡេង ថ ទន្តជៈ ដែលឮស្ទះចេញត្រង់ប្រទល់ធ្មេញ, សំ. បា. ជា ដ្ហៈ ឬ ដ្ហ៌ៈ ស្សជាមុទ្ធជៈ, ផ្សេងគ្នាពី ត្ហៈ ទន្តជៈ, តាមនិគ្គហិតអឃោសៈ, ខាង សំ. បា. គ. ថ. ឋៈ ដ្ហៈ ឬ ថ៌ៈ ត្ហ៌ៈ (បើកមាត់លាស់ចុងអណ្ដាតទៅខាងលើ, កុំឲ្យដូច ថៈ ត្ហៈ ដែលលាស់ចុងអណ្ដាតឲ្យរះត្រង់ប្រទល់ធ្មេញ) ។ ប៉ុន្តែខាងភាសាខ្មែរយើង អានឮ ឋ ថ ដូចគ្នា ។

**ឋបនកម្ម** (ថៈ-ប៉ៈ-ន៉ៈ-កាំ) ន. (បា.) កម្មគឺការតម្កល់ទុកផ្សេងៗ; ដំណើរដែលគេរៀបចំតាក់តែងឡើង, ការធ្វើអ្វីមួយឲ្យកើតឡើងហើយតម្កល់តាំងទុកឲ្យបានឋិតថេរទៅ: *ឋបនកម្មនៃយន្តកម្មវិញ គេបានធ្វើរួចស្រេចហើយ ។*

**ឋបនាការ** (ថៈ-ប៉ៈ-ណាការ) ន. (បា.; សំ. *ស្ថាបនាការ*) ការដែលបិត, ដែលតាំង, ដែលតម្កល់ទៅ: *ឋបនាការរោងចក្រចម្រាញ់ប្រេងកាតនៅក្រុងព្រះសីហនុ ។*

**ឋបនីយកណ្ឌ** (ថៈ-ប៉ៈ-ណី-យ៉ៈ-កាំន) ន. (បា.; សំ. *ស្ថាបនីយកណ្ឌ*) របស់, ទ្រព្យ ដែលគួរតម្កល់ទុក, គួរតាំងទុក, ដែលត្រូវទុកដាក់: *គ្រឿងចក្រទាំងនេះជាឋបនីយកណ្ឌ ត្រូវទុកដាក់ឲ្យល្អ ។*

**ឋបនីយវត្ថុ** (ថៈ-ប៉ៈ-ណី-យ៉ៈ-វ៉ត-ថុ) ន. (បា.; សំ. *ស្ថាបនីយវស្តុ*) វត្ថុដែលគួរតាំងទុក, ដែលត្រូវតម្កល់ទុក: *ចុះគ្រឿងចក្រយើងមានឋបនីយវត្ថុគ្រប់គ្រាន់ទេ?*

**ឋបនោកាស** ន. (បា.) កន្លែងទំនេរសម្រាប់ដាក់, សម្រាប់ទុករបស់ផ្សេងៗ: *ទីនេះចង្អៀតណាស់ អត់មានឋបនោកាសទេ ។*

**ឋបនោបាយ** ន. (បា.) ឧបាយ, គំនិត ដោះទុក ដោះដាក់...: *មានឋបនោបាយល្អ ។*

**ឋាន** ន. (បា.; សំ. *ស្ថាន*) ទី, កន្លែង, តំបន់, ប្រទេស, ទីតាំង, ទីតម្កល់ ។ល។: *ឋានមនុស្ស, ឋានសួគ៌, ឋានព្រហ្ម; នៅឋានណា? មកពីឋានណា?* ។ ពួកឯកដែលលាបថ្នាំទាស់ព័ណ៌: *ឋានស,*



*ឋានលឿង...* ។ ពួកផ្នែកគ្រឿងរចនា ត្រង់ដែលរាប ដែលលើង: *ក្រោមក្បាច់គ្របកណ្ដុក ត្រូវទុកឲ្យមានឋានទំហំ ៤ ធ្នាប់ ។*

**ឋានៈ** (-ន៉ៈ) ន. (បា. *ឋាន*; សំ. *ស្ថាន*) ហេតុ, ដំណើរ, ទំនង: *សេចក្ដីនេះមានឋានៈគួរឲ្យជឿបាន* ។ ងារ, មុខងារ, ថ្នាក់ងារ, ថ្នាក់ស័ក្តិយស: *លោកមានឋានៈជាអ្វី? —មានឋានៈជាផ្នែករាជការក្រសួងសន្តិសុខ; គួរកុំប្រកាន់ឋានៈពេក ។*

**ឋានន្តរ** (ថាន់-ន-ត-រ៉ៈ ឬ ថាន់-ត) ន. (បា.) លំដាប់នៃទី, មុខងារ, ងារ, ថ្នាក់ងារ, ថ្នាក់ស័ក្តិយស: *លោកមានឋានន្តរជាអ្វី? — មានឋានន្តរជាអភិបាលស្រុក, ឋានន្តរជាព្រះបម្រើសម្បត្តិ ។*

**ឋានន្តរសក្តិ** ឬ **—ស័ក្តិ** (ថាន់ន-ត-រ៉ៈ-ស័ក) ន. (បា. សំ.; សំ. *ស្ថានន្តរ + សក្តិ*) អំណាចតាមមុខងារ, បណ្ដាស័ក្តិធំតូចតាមមុខងារ: *អង្គុយតាមឋានន្តរស័ក្តិ* (ម. ព. *សក្តិ* ឬ *ស័ក្តិ* ផង) ។

**ឋានបទ្ម** (ថាន់-ន៉ៈ-ប័ត) ន. (បា. សំ.; បា. *ឋាន + បទុម*; សំ. *ស្ថាន* "ទី, ទីតម្កល់ + *បទ្ម* "ឈូក") ពាក្យនេះខ្មែរយើងគិតប្រកប ប្រើជាឈ្មោះក្បាច់គ្របកណ្ដុកផ្កាប់ផ្ការ ដែលរចនាធ្វើជាជើង, ជាទ្រនាប់ ទ្រព្រះពុទ្ធរូបឬទេវរូប: គ្របកណ្ដុកដែលសំយុងចុះមកក្រោម ហៅថា *ឈូកផ្កាប់*; ដែលផ្ការឡើង ហៅថា *ឈូកផ្ការ*; បើមានតែឈូកផ្កាប់ ឬមានតែឈូកផ្ការក្ដី ឬក៏មានគ្រប់ទាំងផ្កាប់ទាំងផ្ការក្ដី ហៅថា *ឋានបទ្ម* បានដូចគ្នា: *ឋានបទ្មទ្រព្រះពុទ្ធរូប, ឋានបទ្មទេវរូប ។*

**ឋានប្បភេទ** (ថាន់-ប៉ៈ-ភេត) ន. (បា.; សំ. *ស្ថានប្រភេទ*) សេចក្ដីផ្សេងនៃទី, នៃហេតុ, នៃដំណើរ; ការបែក, បំបែកហេតុឬដំណើរ ចែកជាចំនួនប៉ុណ្ណេះប៉ុណ្ណោះ: *ធម៌នេះមានឋានប្បភេទ ១០ យ៉ាង ។*

**ឋានភាព** (ថានៈភាប) ន. ភាពនៃឋានៈ, ដំណើរ ទំនង, លក្ខណៈ, ឋានៈថ្នាក់: *ផ្ទះនោះមានឋានភាពខ្ពង់ខ្ពស់, ឋានភាពនៃត្រកូល, ឋានភាពនៃជីវិត ។*

**ឋានានុក្រម** (ថា-នា-នុ-ក្រំ) ន. (បា. សំ.; បា. *ឋាន + អនុក្កម > ឋានានុក្កម*; សំ. *ស្ថាន + អនុក្រម > ស្ថានានុក្រម*) លំដាប់ឬរបៀប នៃទី, នៃងារ, នៃមុខងារ, នៃស័ក្តិយស ។ ក្នុងកម្ពុជប្រទេសយើង ប្រើពាក្យនេះជាតំណែងនៃសមណស័ក្តិថ្នាក់តូចជាងទីរាជាគណៈ តាមលំដាប់ចុះមក: *និមន្តព្រះភិក្ខុសង្ឃរាជាគណៈ ឋានានុក្រម ៦០ រូបចម្រើនព្រះបរិត្ត ។*

**ឋានានុរូប** (ថា—) គុ. ឬ ន. (បា.; សំ. *ស្ថានានុរូប*) ដែលសមគួរតាមទី, តាមមុខងារ...; ដំណើរ

សមគួរល្មមតាមទំ, តាមជាន់ថ្នាក់ : *ប្រព្រឹត្តតាមឋានានុរូប, អង្គុយតាមឋានានុរូប, កាន់ការតាមឋានានុរូប* ។

**ឋានីយ** (-នី ឬ -ណី) *ន.* (បា.; សំ. *ស្ថានីយ*) ទីសម្រាប់សម្នាក់, ទីសំចត, ទីចត, ទីណាក់សម្រាប់ឈប់សម្រាក, សម្រាប់តាំងទេះជាដើម; ភូមិ, ស្រុក ។ល។ : *ឋានីយរទេះ, ឋានីយរថយន្ត, ឋានីយរទេះភ្លើង* ... (ច្រើនប្រើ *ស្ថានីយ* ជាង *ឋានីយ*) ។

**ឋិត** *គុ.* (បា.; សំ. *ស្ថិត*) តម្កល់, តាំង, តាំងនៅ, នៅ, ឈរ ... (ពាក្យខ្មែរច្រើនប្រើ *ស្ថិត* ជាង *ឋិត*) : *ព្រះមហាក្សត្រិយ៍ទ្រង់ព្រះស្ថិតក្នុងព្រះមហាប្រាសាទ* (ម. ព. *សណ្ឋិត* ទៀតផង) ។

**ឋិតថេរ** *គុ.* (បា. *ឋិត + ថិរ*; សំ. *ស្ថិត + ស្ថិរ*) ដែលឋិតនៅយូរ, ទៀង, ដែលតាំងនៅមាំមួន, ខ្ជាប់ខ្ជួន; ដែលជាប់បានយូរ; ស្ថាពរ : *របស់ឋិតថេរ, ការងារឋិតថេរ* ។ *កិ. វិ.* ដែលមានជាប់យូរមកហើយ មិនដែលដាច់, មិនដែលឈប់ : *ធ្វើការឋិតថេរ* ។

**ឋិតថេរចិរកាល** (-ថេរកាល) *ន.* (បា. *ឋិត + ថិរ + ចិរ + កាល*) កាល, គ្រាដែលឋិតថេរយឺនយូរ (ម. ព. *ឋិតថេរ* និង *ចិរកាល* ទៀតផង) ។

**ឋិតិ** *ន.* (បា.; សំ. *ស្ថិតិ*) ទីតាំង, ជីវិត, ដំណើររស់នៅ; ដំណើរតាំងនៅនៃចិត្ត ... ។ *ឋិតិ* ឬ *ស្ថិតិ* បញ្ចុ ។

**ឋិតិកាល** *ន.* (បា.; សំ. *ស្ថិតិកាល*) កាល, គ្រាដែលតាំងនៅ; កាលនៃការឋិតនៅ ... ។

**ឋិតិភាព** (-ភាព) *ន.* (បា. *ឋិតិភាវ*; សំ. *ស្ថិតិភាវ*) ភាពនៃការឋិតនៅ, ដំណើរដែលឋិតនៅ ... ។